# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

## ការិយាល័យអគ្គនាយកក្រសួងអប់រំ

**440 NORTH BROAD STREET, SUITE 301**
**PHILADELPHIA, PENNSYLVANIA 19130**

**WILLIAM R. HITE, JR., Ed.D.**
*អគ្គនាយក*

ទូរស័ព្ទ៖ (២១៥) ៤០០-៤១០០
ទូរសារ៖ (២១៥) ៤០០-៤១០៤

ជូនចំពោះមាតាបិតា/អាណាព្យាបាល៖

ជាច្រើនសប្តាហ៍មកហើយ បុគ្គលិកទូទាំងក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា បានខិតខំប្រឹងប្រែងដើម្បីរៀបចំសាលារបស់យើងសម្រាប់ ថ្ងៃច័ន្ទ ទី៩ ខែកញ្ញា ដែលជាថ្ងៃចូលរៀនដំបូងសម្រាប់ឆ្នាំសិក្សា ២០១៣-១៤។ ក៏ប៉ុន្តែ យើងនៅតែមិនទាន់ដឹងច្បាស់អំពី ការដំឡើងចំនួនប្រាក់ជំនួយ និង ប្រាក់សន្សំ ដើម្បីជាជំនួយបន្ថែមដល់សាលារបស់យើង។

មកដល់ថ្ងៃនេះ នៅមិនទាន់មានសកម្មភាពអ្វីជាផ្លូវការ ដើម្បីបង្កើនប្រាក់ឧបត្ថម្ភ ដែលអាចឲ្យក្រសួងជួលបុគ្គលិកដែលខំខាន់ៗមកវិញ ដែលគេបានបញ្ឈប់ការងារជាច្រើននាក់ កាលពីខែមិថុនាកន្លងទៅនេះ។ យើងត្រូវការបុគ្គលិកទាំងនោះ ដើម្បីធានាឲ្យសាលារបស់យើងទាំងអស់ដំណើរការណ៍ទៅបានស្រួល និងជាពិសេសគឺមានសុវត្ថិភាព។ ក្នុងខណដែលក្រសួងអាចជួលបុគ្គលិកមួយចំនួនមកវិញ យើងមិនអាចផ្តល់ជំនួយ មិនអាចផ្តល់បុគ្គលិក និងធនធាន សម្រាប់កម្មវិធីក្រៅម៉ោងសិក្សា សិល្បៈ និង ដន្ត្រី ដល់សាលាទាំងអស់ ទៅតាមសេចក្តីត្រូវការរបស់ពួកគេបានទេ។

នៅក្នុងសប្តាហ៍ថ្មីៗនេះ យើងកំពុងរង់ចាំការសម្រេចនៃប្រាក់ឧបត្ថម្ភ ចំនួន ៥០$ លាន ពីសាលាក្រុង។ បើសិនជាក្រសួងមិនបានទទួលប្រាក់ឧបត្ថម្ភនេះនៅថ្ងៃសុក្រ ទី១៦ ខែសីហា នេះទេ យើងនឹងបង្ខំចិត្តឲ្យពន្យាពេលថ្ងៃចូលរៀនដំបូង សម្រាប់សាលាមួយចំនួន ឬសម្រាប់សាលាទាំងអស់ ឬក៏បើកសាលា តែត្រឹមពាក់កណ្តាលថ្ងៃ ប៉ុណ្ណោះ។

ខ្ញុំអាចបញ្ជាក់ប្រាប់លោកអ្នកថា នៅពេលដែលកូនរបស់លោកអ្នក ធ្វើដំណើរតាមរបៀងសាលា ពេលញ៉ាំអាហារថ្ងៃត្រង់ ឬពេលចេញលេង នឹងមានមនុស្សពេញវ័យម្នាក់មើលពួកគេ។ ខ្ញុំអាចបញ្ជាក់ប្រាប់លោកអ្នកថា នាយករង នឹងជួយចាត់ចែងនូវរាល់បញ្ហាវិន័យ ដែលអាចបង្កបញ្ហាដល់ការរៀនសូត្រ។ ខ្ញុំអាចបញ្ជាក់ប្រាប់លោកអ្នកថា នាយកសាលា អាចចេញពីការិយាល័យ ទៅដោះស្រាយបញ្ហា និងអាចជួយដល់បុគ្គលិកនៅតាមកន្លែងផ្សេងៗនៅក្នុងសាលា។ បើសិនជាគ្មានប្រាក់ឧបត្ថម្ភបន្ថែមទេ ខ្ញុំមិនអាចធ្វើកិច្ចការទាំងនេះបានឡើយ។

ទោះជាយ៉ាងណាក៏ដោយ បើគិតទៅ ប្រាក់ ៥០$ លាន បានត្រឹមតែអាចឲ្យយើងបើកទ្វារសាលា តែប៉ុណ្ណោះ។ វាមិនអាចគ្រប់គ្រាន់ឲ្យយើងធ្វើអ្វីៗទាំងអស់ដែលនៅពីក្រោយទ្វារទាំងនោះបានទេ។ យើងត្រូវតែបន្តធ្វើការជាមួយដៃគូផ្នែកការងារ និងមន្ត្រីរបស់រដ្ឋ ដើម្បីធានាការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម។ នេះគឺអាចឲ្យយើង ចៀសវាងបានការដាក់កម្រិតថ្នាក់បញ្ចូលគ្នា បន្តជំនួយដល់ការបង្រៀនដល់សិស្សដែលមានបញ្ហាក្នុងការសិក្សា អនុវត្តជំនួយផ្នែកភាសា ដែលអាចជួយត្រៀមឲ្យសិស្សានុសិស្សរបស់យើងសម្រាប់សេដ្ឋកិច្ចសកលលោក ផ្តល់សកម្មភាពក្រៅម៉ោងសិក្សាដែលអាចជួយបង្កើនបទពិសោធន៍ក្នុងការសិក្សារបស់សិស្ស ផ្តល់មុខវិទ្យាកម្រិតខ្ពស់ដែលអាចលើកកម្ពស់ចំណេះដឹង និងជំនាញរបស់ពួកគេ និងអាចជួយផ្តល់ឱវាទបានគ្រប់គ្រាន់ ដើម្បីជួយពួកគេត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យ។

ខ្ញុំសូមឲ្យលោកអ្នក រៀបចំកូនលោកអ្នកជាស្រេចសម្រាប់ឆ្នាំសិក្សាខាងមុខ ជាមួយនឹងបញ្ជីសៀវភៅសម្រាប់អាន (មាននៅក្នុង វ៉ិបសៃរបស់ក្រសួង) និងសកម្មភាពជួយបង្កើនចំណេះដឹង។ ការចុះឈ្មោះសម្រាប់សិស្សអន្តោប្រវេសន៍ថ្មី នឹងមានដំណើរការណ៍ជាបន្ត ហើយការចុះឈ្មោះសិស្សជាទូទៅ នៅតាមសាលាក្នុងតំបន់ នឹងប្រព្រឹត្តទៅនៅ ថ្ងៃច័ន្ទ ទី១៩ នៃខែសីហា។

យើងខ្ញុំសូមអភ័យទោសចំពោះកាលៈទេសៈដ៏អកុសលនេះ ហើយសង្ឃឹមថានឹងអាចទទួលបានដំណោះស្រាយ ដែលទាក់ទងនឹងបញ្ហាអាសន្នទាំងនេះ យ៉ាងឆាប់រហ័ស។ សូមលោកអ្នកជ្រាបថា យើងខ្ញុំទន្ទឹងរង់ចាំដើម្បីស្វាគមន៍កូនលោកអ្នកក្នុងការវិលត្រឡប់មកសាលាវិញនៅសរទរដូវខាងមុខនេះ។

ដោយសេចក្តីស្មោះស្ម័គ្រ

William R. Hite Jr., Ed.D.
អគ្គនាយក